# លាបសារធាតុការពារការជ្រាបទឹកថ្ងៃនេះ ដើម្បីទប់ស្កាត់ការពុកធ្មេញ

## ការពារធ្មេញកូនរបស់លោកអ្នក ប្រឆាំងទល់នឹងការប្រហោងធ្មេញ

### តើសារធាតុ-ស៊ីឡ្បាន លាបការពារធ្មេញថ្គាមគឺជាអ្វី ?

សារធាតុ-ស៊ីឡ្បាន (sealants) គឺជាសារធាតុថ្លា លាបពីលើធ្មេញថ្គាមទីមួយ និង ទីពីរ ដើម្បីជួយរក្សាថ្គាមទាំងនោះ ឲ្យមានសុខភាពល្អ និងការពារ ការប្រហោងធ្មេញ ។

### តើកូនរបស់ខ្ញុំគួរលាបសារធាតុ-ស៊ីឡ្បាន ការពារធ្មេញ នៅពេលណា?

អ្នកគួរធ្វើការណាត់ជួបពេទ្យធ្មេញ ដើម្បីយកកូនរបស់អ្នកទៅលាបសារធាតុ ស៊ីឡ្បាន នៅពេលធ្មេញថ្គាមពួកគេដុះចេញមក។ ធ្មេញថ្គាមដុះចេញមក ដំបូងបំផុតនៅអាយុ ៥ ឆ្នាំ ។

### តើសារធាតុ ស៊ីឡ្បាន ត្រូវបានលាបដោយរបៀបណា?

ត្រូវធាតុស៊ីឡ្បាន ត្រូវបានលាបនៅលើធ្មេញថ្គាមរបស់កុមារ។ ការលាបគឺលឿន និងមិនឈឺចាប់ទេ! ដំណើរការទាំងមូលប្រើពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។

### តើកូនរបស់ខ្ញុំអាចហូបអាហារបានភ្លាមៗទេ ?

បាទ/ចាស៎! កូនរបស់អ្នកអាចហូបអាហារបាន បន្ទាប់ពីលាបសារធាតុ-ស៊ីឡ្បានរួច។

### តើសារធាតុសារធាតុ-ស៊ីឡ្បាន មានអត្ថប្រយោជន៍អ្វីខ្លះ?

ការលាបសារធាតុ-ស៊ីឡ្បាន គឺមានសុវត្ថិភាពនិង អាចការពារធ្មេញកូនរបស់អ្នក ពីបាក់តេរីចង្រៃ ការប្រហោងធ្មេញ ឬការពុកធ្មេញ។

### តើការលាបសារធាតុ-ស៊ីឡ្បាន មានប្រសិទ្ធិភាព បានយូប៉ុណ្ណា?

ការលាបសារធាតុ-ស៊ីឡ្បាន អាចការពារធ្មេញកុមារបានច្រើនឆ្នាំ! សូមសួរពេទ្យធ្មេញរបស់អ្នក ពេលណាអ្នកគួរយកកូនអ្នក ទៅលាបសារធាតុនេះម្តងទៀត ។

### តើការលាបសារធាតុ-ស៊ីឡ្បាន អាចជំនួសសារធាតុ ផ្លួអរ៉ៃ (fluoride) ដែរឬទេ ?

ទេ! សារធាតុទាំងពីរនេះគឺចាំបាច់ដូចគ្នាក្នុងការ ការពារ កុំឲ្យប្រហោងធ្មេញ ឬពុកធ្មេញ ។

### តើការលាបសារធាតុ-ស៊ីឡ្បាន ត្រូវបាន អត្ថប្រយោជន៍មាត់ធ្មេញ មេឌីកាល់ Medi-Cal ចេញលុយឲ្យឬទេ?

ទេ! សារធាតុទាំងពីរនេះគឺចាំបាច់ដូចគ្នាក្នុងការ កបាទ/ចាស៎! អត្ថប្រយោជន៍មាត់ធ្មេញ មេឌីកាល់ Medi-Cal នឹងចេញលុយ ក្នុងការលាបសារធាតុ-ស៊ីឡ្បាន ការពារធ្មេញរបស់កុមារ និងក្មេងជំទង់រហូតដល់អាយុ ២១ ឆ្នាំ ។



** កុមារដែលមិនបាន លាបសារធាតុ ស៊ីឡ្បាន ប្រឈមមុខនឹងជម្ងឺ ប្រហោងធ្មេញ

ដល់ទៅ ៣ដង លើស កុមារដែលបានលាបសារធាតុ ស៊ីឡ្បាន។

smile, CALIFORNIA™ MEDI-CAL HAS DENTAL COVERED

all in HEALTH CARE FOR ALL FAMILIES — A PROJECT OF The Children's Partnership

**ប្រភព: មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជម្ងឺ Centers for Disease Control and Prevention www.cdc.gov/

សូមចូលទៅគេហទំព័រ **SmileCalifornia.org** ដើម្បីកំនត់ទីតាំងពេទ្យធ្មេញ និងធ្វើការណាត់ជួប ដើម្បីយកកូនរបស់អ្នកទៅលាបសារធាតុការពារធ្មេញ-ស៊ីឡ្បាន។

2023-01-TCP